សារស្តីពីការបះបោរនៅកាពីតុល

ក្រុមគ្រួសារក្រសួងអប់រំឡុងប៊ីចជាទីមេត្រី:

យើងដឹងថាមានសិស្សនិងមាតាបិតាជាច្រើនកំពុងតាមដានស្ថានភាពនៅរដ្ឋធានី វ៉ាស៊ីងតុន ឌីស៊ី បន្ទាប់ពីបាតុកម្មដ៏គួរឱ្យខ្លាចនៅអគារកាពីតុលកាលពីម្សិលមិញ។ ថែមពីនេះទៀត យើងក៏ដឹងអំពីវិបត្តិនយោបាយជាតិនៅក្នុងសប្តាហ៍នេះ ដែលជារឿងមួយទៀតយើងមិនទាន់ដឹងលទ្ធផលច្បាស់លាស់នៅឡើយដែរ បន្ទាប់ពីមានបញ្ហាជាច្រើនខែកន្លងមក។

កាលពីល្ងាចម្សិលមិញ យើងបានចែករំលែកធនធានថ្នាក់រៀនជាមួយគ្រូបង្រៀនសម្រាប់ឱ្យពួកគាត់ប្រើប្រាស ជាគំរូនិងលើកទឹកចិត្តដល់របៀបរៀបរយនៃប្រជាពលរដ្ឋ។ ថែមពីនោះទៀត យើងបន្តផ្តល់ការគាំទ្រផ្នែកផ្លូវចិត្តនិងអារម្មណ៍ ដែលអាចទទួលបានពីគ្រូបង្រៀន អ្នកផ្តល់ឱវាទសាលា និងអភិបាលសាលា។ មជ្ឈៈមណ្ឌលធនធានគ្រួសាររបស់យើងនៅបន្តផ្តល់សេវាកម្មតាមរយៈវ៉េបសាយនៅ lbschools.net ។ សុំចាំថា ការិយាល័យសាលារៀរបស់យើងអាចធ្វើការទាក់ទងបានតាមរយៈទូរស័ព្ទនិងអ៊ីមែល ហើយយើងសូមលើកទឹកចិត្តឱ្យលោកអ្នកទាក់ទងយើងបើលោកអ្នកត្រូវការការគាំទ្រសម្រាប់កូនលោកអ្នក។

ជាជាងស្ថាប័នណាៗទាំងអស់ សាលារៀនរបស់យើងជាថ្នាលបណ្តុះប្រជាធិបតេយ្យចម្រុះមួយ។ យើងបង្រៀនសិស្សឱ្យចេះគិតជ្រៅជ្រះ អំពីការបោះឆ្នោត ហើយនៅក្នុងសមាហរកម្មនយោបាយ យើងផ្តល់ឱកាសឱ្យសិស្សអនុវត្តរបៀបធ្វើទំនាក់ទំនងជាមួយមនុស្សនិងគោលគំនិតដែលមានមតិផ្សេងៗពីគ្នា។ ទាំងនេះគឺជាជំនាញផ្លូវចិត្តនិងអារម្មណ៍និងបំណិនជីវិត ដែលយើងចង់បណ្តុះនៅក្នុងសិស្សរបស់ក្រសួងអប់រំឡុងប៊ីចទាំងអស់។ ទោះបីជាព្រឹត្តិការណ៍ពីម្សិលមិញជាការមួយដ៏ភ្ញាក់ផ្អើល វាក៏ផ្តល់ជាឱកាសមួយសម្រាប់ពិភាក្សាអំពីភាពជាពលរដ្ឋល្អ សមភាពនៃសិទ្ធិ សុវត្ថិភាពនិងចលនាពលរដ្ឋសម្រាប់ការផ្លាស់ប្តូរដល់សង្គម។

ក្រុមអ្នកអប់រំ គ្រូបង្រៀន និងបុគ្គលិកសាលារបស់យើងនៅតែប្តេជ្ញាដល់សុខុមាលភាពរបស់សិស្សយើងជានិច្ច។

ជាមួយអំណរគុណដល់ការគាំទ្ររបស់លោកអ្នក។

Jill

Jill Baker, Ed.D.
អគ្គនាយកនៃការអប់រំ